ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងខេត្តបន្ទាយមានជ័យ

ចៅក្រមបន្ទប់ ( ខ.២ )

លេខៈ ១៦៧៤ ពស.ព្រស "ង.២"/២១

# ដីកាដំណោះស្រាយ

យើង [redacted] ចៅក្រមស៊ើបសួរសាលាដំបូងខេត្តបន្ទាយមានជ័យ

ដោយមានលោក [redacted] ជាក្រឡាបញ្ជីអមផង។

បានឃើញ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា។

បានឃើញ សំណុំរឿងព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ ២២៤ អយក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ ១៣៤ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ២៤៣ អយក ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០២១ របស់អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

ក្រោយពីបានស៊ើបសួរចប់សព្វគ្រប់ហើយឃើញថា ៖

១.ឈ្មោះ [redacted] ឡា ភេទប្រុស កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ សាសនាព្រះពុទ្ធ មុខរបរកសិករ កម្រិតវប្បធម៌ថ្នាក់ទី០៦ថ្មី ទីកន្លែងកំណើតជំរុំសាវដាង ប្រទេសថៃ អាសយដ្ឋា[redacted]ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ប្រពន្ធឈ្មោះ[redacted]មានកូនចំនួន០៥នាក់ ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted] (រ) ជានីតិជន ទោសពីមុន គ្មាន ។ (ក្នុងឃុំ)

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្ដន្ទាទោសតាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្ដីពី ការត្រួតពិនិត្យគ្រឿងញៀន។

២.ឈ្មោះ [redacted] មុំ ភេទស្រី ថ្ងៃខែឆ្នាំកំណើត០៩-០៦-១៩៧៨ សញ្ជាតិខ្មែរ ទីកន្លែងកំណើតភូមិទោលថ្ម ឃុំទោលថ្ម ស្រុកកំពង់សៀម ខេត្តកំពង់ចាម អាសយដ្ឋានភូមិ[redacted]ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ប្ដីឈ្មោះ [redacted] ឪពុកឈ្មោះ [redacted] ម្ដាយឈ្មោះ [redacted]។ (គេចខ្លួន)

៣. ឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា៤២ឆ្នាំ អាសយដ្ឋានក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

៤. ឈ្មោះ វី ភេទប្រុស អាយុប្រហែលជា៣២ឆ្នាំ អាសយដ្ឋានក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ លេខទូរស័ព្ទ [redacted]។

ត្រូវបានដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

ពាក់ព័ន្ធនឹងអង្គហេតុដូចតទៅ ៖ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ កម្លាំងនគរបាលនៃប៉ុស្តិ៍រដ្ឋបាលគោករមៀត បានធ្វើប្រតិបត្តិការបង្ក្រាបករណីជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់សារធាតុញៀន នៅចំណុចភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ដោយឃាត់ខ្លួនបានជនសង្ស័យចំនួន ០១នាក់ ឈ្មោះ [redacted] ឡា។ ឆ្លងកាត់ការសាកសួរនៅដំណាក់កាលសមត្ថកិច្ចឈ្មោះ [redacted] ឡា បានឆ្លើយសារភាពថា ខ្លួនបានទិញគ្រឿងញៀនពីឈ្មោះ ធី ,ឈ្មោះ រី ដែលប្រើប្រាស់លេខទូរស័ព្ទ [redacted] និងឈ្មោះ មុំ ដើម្បីយកមកប្រើប្រាស់ និងរំលែកលក់បន្ត។

១.តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ឡា នៅផ្នែកគ្រឿងញៀន នៃអធិការដ្ឋានស្រុកថ្មពួក កាលពីថ្ងៃទី០៨-០៣-២០២១ ថា បានជាសមត្ថកិច្ចឃាត់ខ្លួនមក មូលហេតុខ្លួនបានយកម្សៅក្រាមសថ្លាចំនួន ១ថង់ធំល្មម និងសំបកថង់ទទេ សម្រាប់ច្រកថ្នាំញៀនមួយចំនួន ដាក់ចូលក្នុងអាវ ហើយយកខោអាវទាំងអស់នោះមកកន្លែងគេបោកគក់ ត្រូវបានអ្នកបោកគក់មានការសង្ស័យ ក៏បានរាយការណ៍ជូនសមត្ថកិច្ច ឃាត់ខ្លួនរូបខ្លួនមកតែម្តង។ ខ្លួនចេះរកស៊ីលក់ថ្នាំញៀនអស់រយៈពេលជាងកន្លះឆ្នាំមកហើយ ។ដោយសារឈ្មោះខ្លួនល្បីពេកខ្លួនក៏ផ្អាកមួយរយៈ។ ដោយថ្នាំញៀនដែលខ្លួនលក់កន្លងមក គឺទិញពីឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា៤២ឆ្នាំ រស់នៅក្នុងប៉ោយប៉ែត ពុំចាំលេខទូរស័ព្ទ។ ថ្នាំញៀនខ្លួន ដែលសមត្ថកិច្ចដកហូតនេះ គឺខ្លួនបានទិញពីឈ្មោះ មុំ ភេទស្រី អាយុ៤៣ឆ្នាំ រស់នៅបន្ទាយមានរិទ្ធ មិនចាំលេខទូរស័ព្ទ រួចខ្លួនបានជិះម៉ូតូយកថ្នាំញៀនគិតជាប្រាក់ ៥៥០.០០០រៀល និងថ្នាំគ្រាប់២គ្រាប់ តែខ្លួនជក់អស់មួយគ្រាប់ នៅសល់មួយគ្រាប់សមត្ថកិច្ចដកហូតបាន ដែលខ្លួនបានបោះចោលក្បែរបង្អួច។

២.តាមកម្លើររបស់ជនត្រូវចោទឈ្មោះ [redacted] ឡា នៅផ្នែកគ្រឿងញៀន នៃអធិការដ្ឋានស្រុកថ្មពួក កាលពីថ្ងៃទី០៨-០៣-២០២១ ដូចគ្នាផងដែរ ថា បានជាសមត្ថកិច្ចឃាត់ខ្លួនមកកាន់ទីនេះ មូលហេតុខ្លួនបានយកម្សៅក្រាមសថ្លា ចំនួន១ថង់ធំល្មម និងសំបកថង់ទទេសម្រាប់ច្រកថ្នាំញៀនមួយចំនួនដាក់ក្នុងអាវ ហើយយកខោអាវទាំងអស់នោះមកកន្លែងគេបោកគក់ ក៏ត្រូវបានអ្នកបោកគក់សង្ស័យក៏រាយការណ៍ជូន ទើបសមត្ថកិច្ចឃាត់ខ្លួនរូបខ្លួន។ ខ្លួនបានរកស៊ីលក់ថ្នាំញៀនអស់រយៈពេលជាងកន្លះឆ្នាំហើយ ។ដោយសារល្បីឈ្មោះខ្លួនច្រើនពេក ខ្លួនក៏បានផ្អាកមួយរយៈ។ ថ្នាំញៀនដែលខ្លួនយកមកលក់ចែកចាយកន្លងមក ខ្លួនបានទិញយកមកពីឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា៤២ឆ្នាំ រស់នៅក្នុងប៉ោយប៉ែត ខ្លួនពុំចាំលេខទូរស័ព្ទ។ ថ្នាំញៀនខ្លួន ដែលសមត្ថកិច្ចបានដកហូតនេះ ខ្លួនបានតេទូរស័ព្ទទិញពីឈ្មោះ រី ភេទប្រុស អាយុប្រហែលជា៣២ឆ្នាំ រស់នៅប៉ោយប៉ែត ប្រើប្រាស់លេខទូរស័ព្ទ [redacted]។ កាលពីម្សិលមិញនៅម៉ោងប្រហែលជាពីររសៀល ខ្លួនតេទូរស័ព្ទទៅឈ្មោះ រី ឱ្យផ្ញើថ្នាំមកឱ្យ ខ្លួនក៏បានទទួលថ្នាំនោះ(ម្សៅក្រាមសថ្លា) គិតជាប្រាក់ចំនួន ៥០០.០០០រៀល ហើយក៏បានយកទៅលាក់ក្នុងអាវ ហើយម្សៅក្រាមសថ្លានេះពិតជារបស់ខ្លួនប្រាកដមែន។ ចម្លើយរបស់ខ្លួនចប់តែត្រឹមនេះ ហើយសុទ្ធតែជាពាក្យពិត ពុំមានអ្នកណាម្នាក់ ឬសមត្ថកិច្ចបង្ខិតបង្ខំឡើយ។

៣.តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ឡា នៅដំណាក់កាលអយ្យការ ខ្លួនសូមប្ដឹងជំទាស់ចម្លើយដែលបានឆ្លើយនៅដំណាក់កាលសមត្ថកិច្ចកាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ទាំងអស់ព្រោះតែ



Scanned with CamScanner

សមត្ថកិច្ចបានតំរាមខ្លួនយកចម្លើយ និងសូមបន្ថែមចម្លើយដូចខាងក្រោម កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោងប្រហែលជា ១១ ថ្ងៃ ពេលខ្លួនកំពុងតែបោសសំអាតផ្ទះរបស់ខ្លួន ក៏ស្រាប់តែមានសមត្ថកិច្ចបានមកឃាត់ខ្លួនយកមកសួរនៅប៉ុស្តិ៍នគរបាលរដ្ឋបាលគោករមៀត ពាក់ព័ន្ធនឹងករណី ជួញដូរគ្រឿងញៀន ព្រោះតែសមត្ថកិច្ចបានរកឃើញគ្រឿងញៀនចំនួន ០១ កញ្ចប់ដែលលាក់ទុកនៅក្នុងខោអាវរបស់ខ្លួន ដែលយកទៅឱ្យគេបោកគក់។ ខ្លួនមិនដឹងហេតុអ្វីបានជានៅក្នុងខោអាវដែលខ្លួនឱ្យគេបោកគក់នោះ មានបង្កប់គ្រឿងញៀននៅក្នុងនោះទេ។ កាលពីថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ វេលាម៉ោង០៨ព្រឹក ពេលខ្លួនកំពុងតែនៅផ្ទះ ក៏មានប្ដីរបស់ឈ្មោះ [redacted] សួង ដែលរកស៊ីបោកខោអាវនៅតាមភូមិ បានមកប្រមូលខោអាវរបស់ខ្លួន និងប្រពន្ធរបស់ខ្លួនយកទៅបោកនៅផ្ទះរបស់ឈ្មោះ[redacted] សួង ដែលស្ថិតនៅក្បែរផ្សារបឹងត្រកួន ហើយក្រោយមកក៏មានសមត្ថកិច្ចបានមកឃាត់ខ្លួន ពាក់ព័ន្ធនឹងករណីរកឃើញគ្រឿងញៀនដែលលាក់ទុកនៅក្នុងខោអាវដែលខ្លួនយកទៅឱ្យគេបោកចំនួន០១កញ្ចប់។ បានជាខ្លួន និងប្រពន្ធជួលឈ្មោះ[redacted] សួង ឱ្យជួយបោកខោអាវឱ្យនោះ ដោយសារតែខ្លួនមានការរវល់នឹងការងារ ចំណែកឯប្រពន្ធរបស់ខ្លួនក៏កំពុងតែមានជំងឺផងដែរ ទើបគ្មាននរណាជាអ្នកបោកខោអាវនោះទេ ហើយណាមួយឈ្មោះ [redacted]សួង ធ្លាប់មកយកខោអាវរបស់ខ្លួនយកទៅបោកគក់ប្រហែលជា ០៤ ទៅ០៥ដងមកហើយ។ ខ្លួនធ្លាប់មានជម្លោះជាមួយប្អូនស្រីរបស់ ឡាយ សួង ឈ្មោះ [redacted] ស៊ីង ពាក់ព័ន្ធនឹងករណី ខ្ចីប្រាក់ ដោយខ្លួនធ្លាប់ខ្ចីប្រាក់ពីឈ្មោះ[redacted] ស៊ីង ហើយសងទៅវិញមានភាពយឺតយ៉ាវ ទើបបណ្ដាលឱ្យឈ្លោះគ្នាតែម្ដង។ គ្រឿងញៀនដែលសមត្ថកិច្ចបានរកឃើញនៅក្នុងខោអាវរបស់ខ្លួនយកទៅឱ្យឈ្មោះ [redacted] សួង បោកគក់នោះ គឺបិនបែនជារបស់ខ្លួន ដែលដកហូតពីលើខ្លួននោះទេ។ ចំពោះគ្រឿងញៀនដែលសមត្ថកិច្ចថាជារបស់ខ្លួននោះ គឺមិនមែន។ ចំពោះឈ្មោះ រី និងឈ្មោះ ធី ដែលខ្លួនបានឆ្លើយប្រាប់ថា ជាអ្នកលក់គ្រឿងញៀនឱ្យខ្លួននោះ ពីខ្លួនមិនស្គាល់អ្នកទាំង០២ នាក់នោះទេ។ ហើយចំពោះគ្រឿងញៀនចំនួន០១គ្រាប់ ពណ៌ក្រហម ប្រភេទគ្រាប់មានអក្សរ WY ដែលសមត្ថកិច្ចរកឃើញនៅក្បែរបង្អួចផ្ទះរបស់ខ្លួននោះ គឺខ្លួនទិញទុកសម្រាប់ប្រើប្រាស់ប៉ុណ្ណោះ។ ខ្លួនបច្ចុប្បន្នមានមុខរបរចិញ្ចឹមមាន់ និងមានចម្ការដាំដំឡូងទំហំជិត៥០ហិចតា ស្ថិតនៅភូមិវល្លិ៍ប្រេង ឃុំគោករមៀត ស្រុកថ្មពួក ដោយរកចំណូលបានប្រហែល ០៥ ទៅ ០៦លានរៀល ក្នុងមួយខែហើយចំណាយក្នុងមួយខែៗអស់ប្រហែលជា០៣លានរៀល។ ខ្លួនចេះប្រើប្រាស់គ្រឿងញៀនប្រភេទគ្រាប់ ពណ៌ក្រហម ហើយក្នុងមួយសប្ដាហ៍ខ្លួនប្រើប្រាស់អស់ប្រហែលជា០២គ្រាប់ តម្លៃ២០,០០០រៀល ដោយទិញពីឈ្មោះ មុំ ភេទស្រី អាយុប្រហែលជាង៤០ឆ្នាំ រស់នៅភូមិបន្ទាយមានរិទ្ធ ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ។

៤. តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ[redacted] ឡា នៅចៅក្រមស៊ើបសួរថា ខ្លួនបានឆ្លើយនៅកន្លែងប៉ូលីស និងអយ្យការរួចហើយ តែចម្លើយដែលនៅកន្លែងប៉ូលីសមិនត្រឹមត្រូវទេ ព្រោះគេរកវាយខ្លួន បើខ្លួនមិនឆ្លើយគេនឹងវាយខ្លួន ទើបខ្លួនគិតហើយក៏ឆ្លើយទៅ តែថ្នាំញៀនមិនមែនជារបស់ខ្លួនទេ។ ចំពោះចម្លើយដែលឆ្លើយនៅតុលាការជាន់ក្រោម(អយ្យការ) គឺត្រឹមត្រូវ។ ថ្ងៃទី០៧ ខែមីនា ឆ្នាំ២០២១ ម៉ោងប្រហែលជាដប់ ទៅដប់មួយថ្ងៃត្រង់ ពេលខ្លួនកំពុងតែបោសផ្ទះ ស្រាប់តែសមត្ថកិច្ចចូលទៅឃាត់ខ្លួន ហើយបញ្ជូនខ្លួនមកប៉ុស្តិ៍ភ្លាម ដោយមិនបានឆែកឆេរផ្ទះ និងខ្លួនប្រាណខ្លួនទេ។ និងពេលមកដល់ប៉ុស្តិ៍គេសួរចម្លើយ ហើយបញ្ជូនខ្លួនមកស្រុកថ្មពួក ទើបបង្ហាញថ្នាំញៀនថាជារបស់ខ្លួនដែលដកយកពីខោអាវ ដែលខ្លួនដាក់ឱ្យគេបោកខោអាវ ដូច្នេះខ្លួនសូមបដិសេធវិញថាថ្នាំញៀនមិនមែនជារបស់ខ្លួនទេ។ ខ្លួនចេះប្រើប្រាស់ថ្នាំញៀន ដែលប្រើប្រាស់លើកចុងក្រោយគឺមុនថ្ងៃសមត្ថកិច្ចចាប់ខ្លួនមួយថ្ងៃ ដែលខ្លួនប្រើប្រាស់នៅនឹងផ្ទះ ថ្នាំញៀនប្រភេទគ្រាប់



Scanned with CamScanner

ដែលខ្លួនទិញពីគេម្តងពីរគ្រាប់ យកមកប្រើមួយគ្រាប់នៅសល់មួយគ្រាប់ ខ្លួនក៏សៀតទុកនឹងហោប៉ៅខោ និងត្រូវបានជ្រុះពេលចាប់ខ្លួន បានក្រោយមកគេទៅដកហូតយកមក។ ចំពោះថ្នាំញៀនដែលខ្លួនថាមិនមែនជារបស់ខ្លួន ហើយប៉ូលីសថាជារបស់ខ្លួន នោះគឺប្រភេទទឹកកក។ ខ្លួនចង់បញ្ជាក់ជូនថា ខ្លួនមិនបានលក់ថ្នាំញៀនទេ។ ថ្នាំញៀនខ្លួនទិញយកមកប្រើប្រាស់ទិញពីឈ្មោះ មុំ ភេទស្រី អាយុ៥០ជាងតិចតួច មានប្តីឈ្មោះ ភាព មុខរបរបើកការ៉ាអូខេ នៅបឹងគ្រកូន ជិតផ្សារ រស់នៅភូមិបឹងគ្រកូន។ ចំពោះឈ្មោះ រី និងឈ្មោះ ធី ខ្លួនមិនស្គាល់ទេ តែខ្លួនបានឆ្លើយនៅកន្លែងសមត្ថកិច្ច ព្រោះបើមិនឆ្លើយគេនឹងវាយ ទើបខ្លួនបង្កើតឈ្មោះ រី និងឈ្មោះ ធី ឡើងមក កុំឱ្យគេវាយ។ ខ្លួនក៏បាននាំសមត្ថកិច្ចទៅរកឈ្មោះ មុំ ដល់ផ្ទះដែរ តែគេចខ្លួនបាត់ហើយ។

៥. តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ហូរ ហៅញ៉ាញ់ នៅប៉ុស្តិ៍នគរបាលរដ្ឋបាលគោករមៀត ថា នៅថ្ងៃទី០៨-០៣-២០២១ ម៉ោងប្រហែលជា១០៖០០នាទី ខ្លួនបានជិះម៉ូតូដើរយកខោអាវបោកអ៊ុតដូចសព្វដង នៅតាមភូមិ ខ្លួនបានទៅយកខោអាវនៅផ្ទះចៃម្នាក់នៅភូមិស្លែប្រេង(ច្រកអូរបីជាន់) ខ្លួនពុំស្គាល់ឈ្មោះ ដឹងត្រឹមតែថាគាត់ជាកូនប្រសាររបស់ចៃរ៉ាត់ ម្ចាស់លានដំឡូងភូមិស្លែប្រេង ហើយចៃម្ចាស់ខោអាវគាត់បានប្រមូលខោអាវដាក់ក្នុងថង់ខ្មៅធំមួយលើកមកឱ្យខ្លួន ៗក៏បានដឹកខោអាវនោះមកផ្ទះហើយមិនបានដើរយកខោអាវកន្លែងផ្សេងទៀតទេ ខ្លួនក៏បានរៀបចំរើខោអាវនោះចេញពីថង់ខ្មៅធំនោះ ដើម្បីដាក់ចូលម៉ាស៊ីនបោក ខ្លួនបានយកខោអាវដាក់ចូលម៉ាស៊ីនអស់ប្រហែលជាពាក់កណ្តាលខ្លួនក៏បំរុងរើយកខោអាវ ដែលនៅសល់ក្នុងថង់ ក៏ស្រាប់តែឃើញមានថង់ដៃពណ៌ខ្មៅមួយនៅក្រោមខោអាវដែលនៅសល់ក្នុងថង់ខ្មៅធំដាក់ខោអាវនោះ ខ្លួនចង់ដឹងថាថង់នោះមានអីក៏យកដាក់លើគ្របពាងស្រាយមើលក៏ឃើញមានម្សៅពណ៌ស ច្រកថង់សមួយដុំ និងមានថង់ពណ៌សតូចៗជាច្រើន ឃើញដូចនោះខ្លួនមានការសង្ស័យថាជាគ្រឿងញៀន ក៏មករាយការណ៍ជូនសមត្ថកិច្ចឱ្យទៅមើល ពេលសមត្ថកិច្ចទៅដល់ គាត់ក៏បានពិនិត្យ ម្សៅសក្នុងថង់នោះ ពួកគាត់ក៏យកមកប៉ុស្តិ៍ និងហៅខ្លួនមកសាកសួររឿងហេតុនៅនឹងប៉ុស្តិ៍ បានមួយសន្ទុះប្រពន្ធខ្លួនបានតេ តាមទូរស័ព្ទមកសួរនាំខ្លួនថា មានចៃម្ចាស់ខោអាវ ថង់ខ្មៅធំនោះ មកសួរខ្លួនថាមិនឃើញទេ ហើយខ្លួនក៏បានបិទទូរស័ព្ទទៅ ព្រោះខ្លួនកំពុងរាយការណ៍ជូនសមត្ថកិច្ចខ្លាចបែកការ។

៦. តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] រ៉េត ជានាយប៉ុស្តិ៍បានឆ្លើយថា ចំពោះករណីដែលពាក់ព័ន្ធនឹងឈ្មោះ [redacted] ឡា ខ្លួនសូមរៀបរាប់ជូនថា ថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ម៉ោងប្រហែលជា១១ថ្ងៃត្រង់ មានអ្នកប្រកបរបរបោកអ៊ុតឈ្មោះ [redacted] ហូរ ភេទប្រុស អាយុ៣៦ឆ្នាំ បានមករាយការណ៍ថា គាត់ជាអ្នកដើរប្រមូលខោអាវតាមផ្ទះមកបោកអ៊ុត ហើយពេលដែលយកខោអាវរបស់ឈ្មោះ [redacted] ឡា គឺប្រពន្ធរបស់ឈ្មោះ [redacted] ឡា យកចេញពីផ្ទះមកឱ្យគាត់ ៗក៏បានយកមកដល់ផ្ទះគាត់ ហើយបានរៀបចំបោកគក់ដោយរើយកចេញពីថង់មកបានពាក់កណ្តាល ស្រាប់តែឃើញថង់ខ្មៅមួយ គាត់មានការឆ្ងល់ ទើបគាត់យកដាក់មកលើគម្របពាង ហើយបានស្រាយមើលឃើញម្សៅក្រាមសថ្លា និងថង់ច្រកតូចៗ សង្ស័យថាជាគ្រឿងញៀន ក៏ជិះម៉ូតូមករាយការណ៍ នៅនឹងទីស្នាក់ការប៉ុស្តិ៍។ ខ្លួនក៏បានឱ្យកំលាំងរបស់ខ្លួនម្នាក់ឈ្មោះ [redacted] សុឃី ជាមន្ត្រីនគរបាលប៉ុស្តិ៍ ទៅជាមួយនឹងអ្នកបោកខោអាវដើម្បីពិនិត្យ ឃើញដូចការរាយការណ៍ ពិតជាថ្នាំញៀនប្រភេទម៉ាទឹកកក ហើយក៏ចាប់ដកយកវត្ថុតាងមកប៉ុស្តិ៍តែម្តង។ បន្ទាប់ពីបានឃើញវត្ថុដែលចាប់មកហើយ ខ្លួនក៏បានរាយការណ៍ទៅអធិការស្រុក ហើយបានរាយការណ៍ផ្ទាល់ទៅឧត្តមសេនីយ៍ស្នងការខេត្តផ្ទាល់ផងដែរ និងប៉ុស្តិ៍ បានបទបញ្ជាពីឧត្តមសេនីយ៍ស្នងការឱ្យទៅនាំខ្លួនឈ្មោះ [redacted] ឡា ពីផ្ទះមកប៉ុស្តិ៍ រួចប្រគល់ឱ្យខាងជំនាញ



Scanned with CamScanner

របស់អធិការស្រុកថ្មពួក និងមានលោកស្នងការរងឈ្មោះ[redacted]ដេត ដែលមានវត្តមាន នៅនឹងប៉ុស្តិ៍ធ្វើការសាកសួរ ហើយខាងខ្លួនចូលរួមស្តាប់ និងចូលរួមស៊ីញ៉េលើកំណត់ហេតុ។ ពាក់ព័ន្ធនឹងដីកាកោះរបស់ឈ្មោះ [redacted] ហួរ ដែលតុលាការបានធ្វើការកោះហៅ ខាងប៉ុស្តិ៍ក៏បានទទួលដែរ និងបានឱ្យកំលាំងប៉ុស្តិ៍ដែលមានឈ្មោះ[redacted] ញូន ធ្វើការបញ្ជូនទៅដល់ផ្ទះគាត់ដែរ តែឃើញនៅតែប្រពន្ធគាត់ឈ្មោះ យិន លៃសួរ កំពុងតែប្រកបអាជីវកម្មបោកអុត ចំណែកឈ្មោះ [redacted] ហួរ មិននៅទេ ហើយពេលកំលាំងប៉ុស្តិ៍យើងទាក់ទងតាមទូរស័ព្ទទៅឈ្មោះ [redacted] ហួរ បែរជាឈ្មោះ [redacted] ហួរ បញ្ជាក់ថា បានទៅនៅស្រុកវិញបាត់ហើយតាំងពីពេលដែលមានរឿងហេតុកើតឡើង ព្រោះបារម្ភពីសុវត្ថិភាព។ ប៉ុន្តែមុនមកឆ្លើយបំភ្លឺនេះមួយថ្ងៃឈ្មោះ [redacted] ហួរ ក៏បានទាក់ទងមកខ្លួន ប្រាប់ថាគាត់មិនមានលទ្ធភាពឡើងមកបំភ្លឺទេ។ ឈ្មោះ [redacted] ហួរ មានលេខទូរស័ព្ទ [redacted]។ ឈ្មោះ[redacted] ហួរ ជាមនុស្សយ៉ាងម៉េចខ្លួនមិនដឹងទេ ព្រោះខ្លួនទើបធ្វើការក្នុងតួនាទីជាមេប៉ុស្តិ៍ បានរយៈពេលមួយឆ្នាំជាងប៉ុណ្ណោះ ហើយឈ្មោះ [redacted] ហួរ ក៏ជាអ្នកចំណូលថ្មីដែរ ដែលគាត់មកនៅប្រហែលជាបីឆ្នាំហើយ។ ចំពោះឈ្មោះ [redacted] ឡា វិញ ខ្លួនសូមបញ្ជាក់ថា ក្នុងរយៈពេលខ្លួនកាន់តួនាទីនៅនឹងប៉ុស្តិ៍មួយឆ្នាំជាង ហើយប្រហែលជាប្រាំទៅប្រាំមួយខែចុងក្រោយនេះ ក៏បានស៊ើប និងលឺព័ត៌មានថាឈ្មោះ [redacted] ឡា មានការពាក់ព័ន្ធនឹងការប្រើប្រាស់ និងចែកចាយដែរ តាមការជំនាញស៊ើបអង្កេត ខ្លួនសូមបញ្ជាក់ឡើងវិញថា បន្ទាប់ពីខ្លួនធ្វើការទាក់ទងបញ្ជាក់ជាមួយខាងមន្ត្រីជំនាញស្រុកហើយ និងមន្ត្រីប៉ុស្តិ៍រួចមកខាងខ្លួនមិនដែលបានទទួលបញ្ជាណា ឱ្យធ្វើការស្រាវជ្រាវអត្តសញ្ញាណរបស់ឈ្មោះ [redacted] ឡា នេះទេ តែអាចមានការសួរនាំតាមទូរស័ព្ទ អំពីអត្តសញ្ញាណរបស់ឈ្មោះ [redacted] ឡា ទើបធ្វើឱ្យមានការយល់ច្រឡំ។ ហើយការបញ្ជាក់ថា មានការចាប់បាន អ្នកប្រើប្រាស់ឆ្លើយថា បានពីឈ្មោះ[redacted] ឡា និងអ្នកប្រើប្រាស់បានបញ្ជូនទៅមណ្ឌលដែរនោះ មិនមានទេ តែមានការបញ្ជាក់ផ្ទាល់មាត់ មិនមានឯកសារបញ្ជាក់ឡើយ។ ចំពោះការដាក់បន្ទុកទៅលើឈ្មោះ[redacted] ឡា បន្ថែម ក្រៅពីសំណុំរឿងខ្លួនពុំមានអ្វីបន្ថែមទៀតទេ។ ឈ្មោះ[redacted] ឡា ជាកូនចុងរបស់មេឃុំគោករមៀត។ ឈ្មោះ [redacted] ឡា មានម្តាយឈ្មោះ រ៉ាត់ ជាអ្នករកស៊ីលានដំឡូង មានចំការដំឡូងខ្លួនឯង ហើយឈ្មោះ[redacted] ឡា និងប្រពន្ធ ជួយធ្វើការងារឱ្យម្តាយ ព្រោះម្តាយមានចំការច្រើន។

៧. តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សំរេច ជានាយរងប៉ុស្តិ៍បានឆ្លើយថា ខ្លួនជាអ្នកដែលទទួលបញ្ជាពីមេប៉ុស្តិ៍ ដើម្បីចុះទៅហៅឈ្មោះ [redacted] ឡា ពីផ្ទះរបស់គាត់មកប៉ុស្តិ៍ និងពេលទៅនោះគឺខ្លួនទៅបីនាក់មានខ្លួន ឈ្មោះ [redacted] សុឃី និងឈ្មោះ [redacted] ញូន បន្ទាប់ពីនាំឈ្មោះ [redacted] ឡា មកដល់ប៉ុស្តិ៍ហើយភ្លាមមេប៉ុស្តិ៍បញ្ជាឱ្យទៅនៅយាមផ្ទះរបស់ឈ្មោះ [redacted] ឡា វិញភ្លាម ហើយពួកខ្លួនក៏ទៅ តែនៅយាមក្រៅផ្ទះ គ្រាន់តែក្នុងបរិវេណរបង រហូតកន្លះម៉ោងក្រោយទើបជំនាញពីខេត្តដល់ ដោយមានស្នងការរង ម្នាក់ជាអ្នកដឹកនាំមិនមានខាងអយ្យការទេ ហើយខាងជំនាញបានស្នើសុំឆែកឆេរផ្ទះ ដោយមានការយល់ព្រម របស់បងប្អូនរបស់ឈ្មោះ [redacted] ឡា និងពេលឆែកឆេររកអ្វីមិនឃើញទេ បានខ្លួនផ្ទាល់ធ្វើការដើរឆ្វែលជុំវិញផ្ទះ ក៏បានឃើញថ្នាំមួយគ្រាប់ទើបធ្វើការចាប់ដកហូតមកធ្វើជាភស្តុតាង ហើយពេលមកដល់ប៉ុស្តិ៍ក៏មិនបានធ្វើអ្វីបន្ថែមទៀតដែរ គឺខាងជំនាញគេអ្នកធ្វើទាំងអស់។

៨.តាមចម្លើយរបស់សាក្សីឈ្មោះ[redacted]លៃសួន (ហួន) ជាប្រពន្ធរបស់សាក្សីឈ្មោះ [redacted] ហួរ [illegible] ឆ្លើយថា ខ្លួនមានប្តីមុនឈ្មោះ [redacted] សុធារី បានលែងលះគ្នាតាំងពីកូនខ្លួនទីពីរមិនទាន់[illegible]បីខែ [illegible] កូនទីពីរខ្លួន អាយុ១១ឆ្នាំ តែពួកវាទៅរស់នៅជាមួយមីងមា នៅស្រុកកំណើត បាន[illegible]ឆ្នាំហើយគិតដល់ពេលនេះ ចំណែកខ្លួនរស់នៅម្នាក់ឯង លើដីដែលម្តាយខ្លួនបន្សល់ឱ្យ ដោយប្រកបរបរបោកអុត និងធ្វើចំការ។



Scanned with CamScanner

ចំពោះប្តីខ្លួនឈ្មោះ ញ៉ាញ់ នេះ គឺស្គាល់គ្នាតាមទូរស័ព្ទ បានប្រហែលកន្លះខែ ក៏យកគ្នាជាប្តីប្រពន្ធតែម្តងទៅ ដោយសារតែគាត់អង្វរសុំរស់នៅជាមួយ តែពេលរស់នៅជាមួយគ្នា មើលទៅគាត់ដូចជាមនុស្សឡប់ៗ ម៉េចមិនដឹង និយាយមិនសូវដឹងអ្វី ដូរឡេះមិនត្រូវគ្នាទេ ហើយតាំងពីថ្ងៃដែលជាប៉ូលីសចុះទៅដល់ផ្ទះនោះមក គឺបាត់គាត់មិនដឹងទៅណាទេ តែថ្ងៃដែលប៉ូលីសចុះនោះ ខ្លួនមិនដឹងរឿងអីផង ព្រោះខ្លួនមិនបាននៅផ្ទះទេ គឺខ្លួនទៅនៅចំការប្រហែលជាមួយខែជាងហើយ ព្រោះឈ្លោះគ្នាជាមួយគាត់ រហូតទាល់តែមានអ្នកជិតខាង គេប្រាប់ថាផ្ទះចំហរទ្វារចោល ហើយពីថ្ងៃមានប៉ូលីសចុះមក មិនដឹងមានរឿងអី ទើបខ្លួនចេញពីចំការមកផ្ទះ ដោយដល់ផ្ទះម៉ោងប្រហែលជាប្រាំពីរយប់ ឃើញផ្ទះចំហរទ្វាចោល មិនឃើញប្តីខ្លួន តាំងពីពេលនោះមក មិនឃើញប្តីខ្លួននោះទេ ទោះបីទូរស័ព្ទក៏គេមិនចូលដែរ។ ប្តីខ្លួនឈ្មោះ ញ៉ាញ់ នេះ មិនដឹងគាត់មានស្រុកកំណើតនៅទីណាទេ ព្រោះពេលសួរម្តងថានៅពោធិ៍សាត់ និងម្តងថានៅស្វាង ខ្លួនក៏ឈប់សួរទៅ ព្រោះរាល់ពេលដែលនិយាយគ្នាគឺឈ្លោះគ្នារហូត។ ខ្លួនសូមបញ្ជាក់ពួកខ្លួនមិនបានរៀបការទេ គឺស្រឡាញ់គ្នា ក៏មកនៅជុំគ្នាតែម្តងទៅ មិនមានអ្នកណាដឹងលឺ ក្រៅពីអ្នកជិតខាងទេ សូម្បីម៉ែឪបងប្អូនរបស់គាត់ក៏មិនដែលឃើញមក ឬជួបខ្លួនបានស្គាល់គ្នាដែរ។ ខ្លួននឹងប្តីខ្លួនគឺ បានគ្នាជាប្តីប្រពន្ធប្រហែលជាប្រាំបីខែហើយ តែសាច់ដែលនៅជាមួយគ្នាបានប្រហែលជាពីរខែប៉ុណ្ណោះ សូម្បីតែបានគ្នាភ្លាម គឺរស់នៅជាមួយគ្នាបានតែកន្លះខែប៉ុណ្ណោះ គាត់ក៏ខឹង ហើយវេចខោអាវទៅបាត់បានយូរក៏មកវិញ សរុបទៅគាត់រត់ចោលខ្លួនប្រហែលជាដប់ពីរដងហើយ ៗរឿងមិនមានអ្វីធំដុំទេ គឺរឿងប្រាប់ឱ្យធ្វើការងារប៉ុណ្ណោះឯង។ ប្តីខ្លួនគាត់មានពាក់ព័ន្ធនឹងរឿងគ្រឿងញៀន ឬអត់ខ្លួនមិនដឹងទេ តែគាត់ធ្លាប់ខឹងក់រពេល វាយពាង របស់របរដែរ ប៉ុន្តែមិនដែលវាយខ្លួនទេ។ ចំពោះឈ្មោះ [redacted] ឡា ខ្លួនស្គាល់ និងដឹងថាគាត់ជាមនុស្សក្នុងភូមិឃុំ ហើយក៏មិនដែលលឺថាគាត់មានការពាក់ព័ន្ធនឹងគ្រឿងញៀននោះទេ តែគាត់មានការពាក់ព័ន្ធឬអត់ខ្លួនមិនដឹងទេ។ ចំពោះរឿងគ្រឿងញៀន កន្លែងបោកអ៊ុត ដែលប្តីខ្លួនថាជារបស់ឈ្មោះ [redacted] ឡា នេះ ខ្លួនមិនបានដឹងទេ ព្រោះខ្លួនមិនបាននៅផ្ទះ តែសំដីរបស់ប្តីខ្លួននិយាយមកខ្លួនមិនសូវជឿជាក់ទេ ព្រោះធ្លាប់កុហកខ្លួនសូម្បីតែកន្លែងកំណើតម្តងទីនេះម្តងទីនោះ។ ចំពោះចម្លើយរបស់ប្តីខ្លួនដែលថា "*ហៅខ្លួនមកសាកសួររឿងហេតុនៅនឹងប៉ុស្តិ៍អង្គុយបានមួយសន្ទុះ ប្រពន្ធខ្លួនបានទៅតាមទូរស័ព្ទមកសួរនាំខ្លួនថា មានតែម្ចាស់ខោអាវថង់ខ្មៅធំនោះមកសួររកថា មានឃើញកញ្ចប់ឥវ៉ាន់ក្នុងថង់ខោអាវនឹងអត់*" នេះគឺខ្លួនជាប្រពន្ធគាត់មិនបានតេរកគាត់ទេ ព្រោះខ្លួនមិនបាននៅផ្ទះផង ហើយក៏មិនបានដឹងរឿងទៀត ដោយមានអ្នកជិតខាង អាចបញ្ជាក់ថា ខ្លួនមិនបានដឹងរឿង ហើយខ្លួននឹងផ្តល់ភស្តុតាង ដើម្បីបញ្ជាក់រឿងនេះ ។

៩.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted]ប៉ាន់ ថា ក្នុងនាមជាសាក្សីខ្លួនសូមរៀបរាប់ជូនតុលាការថា ខ្លួនជាអ្នកជិតខាងជាមួយឈ្មោះ លៃសួន ដែលមានប្តីឈ្មោះ ញ៉ាញ់ ដោយរស់នៅក្នុងភូមិជាមួយគ្នា តែផ្ទះឃ្លាតគ្នាប្រហែលជាហាសិបម៉ែត្រប៉ុណ្ណោះ និងរស់នៅរាប់អានគ្នា សូម្បីតែពេលឈ្មោះ លៃសួន ឈ្លោះគ្នាជាមួយប្តី គឺបានទៅរស់នៅ និងដេកនៅចំការរបស់ខ្លួន ជួយដាំដំណាំនៅនឹងចំការរបស់ខ្លួន ហើយយកផលរៀងៗខ្លួន ព្រោះខ្លួនជាស្ត្រីមេម៉ាយ ពីមុនឈ្មោះ លៃសួន ក៏ជាស្ត្រីមេម៉ាយដែរ។ នៅថ្ងៃដែលផ្ទះវាមានរឿង ពីដំបូងក៏ខ្លួនមិនបានដឹងដែរ តែថ្ងៃនោះខ្លួនត្រូវចេញពីចំការមកផ្ទះ ម៉ោងជិតប្រាំពីរយប់ ដើម្បីយកអង្ករ និងព្រលឹមក៏នៅបានលឺថា ផ្ទះរបស់ឈ្មោះ លៃសួន មានបញ្ហា តែមិនដឹងបញ្ហាអីទេ និងលឺថាប្តីវារត់បាត់ ផ្ទះចំហរទ្វារចោល ទើបខ្លួនទៅមើលឃើញផ្ទះវាចំហទ្វារចោលមែន ខ្លួនក៏ត្រឡប់ទៅចំការប្រាប់ឈ្មោះ លៃសួន ហើយបានជិកឈ្មោះ លៃសួន មកមើលផ្ទះវាទៀតផង ដោយឈ្មោះ លៃសួន ចូលផ្ទះរកប្តីមិនឃើញមែន ហើយគេ

បានបិទទ្វារ រួចនាំគ្នាត្រឡប់ទៅចំការវិញ។ ខ្លួនក៏សូមបញ្ជាក់ផងដែរថា ឈ្មោះ លៃ សួន ឈ្មោះគ្នាជាមួយប្តីវាឈ្មោះ ញ៉ាញ់ ហើយវាក៏បានទៅរស់នៅចំការជាមួយខ្លួន ដេកជាមួយខ្លួនរយៈពេលប្រហែលមួយខែ ហើយរហូតដល់ថ្ងៃដែលមានបញ្ហាខាងលើនេះ។ ចំពោះឈ្មោះ ញ៉ាញ់ ជាមនុស្សយ៉ាងម៉េចខ្លួនមិនច្បាស់ទេ តែពេលនិយាយគ្នាជាមួយគាត់ និងមើលការនិយាយស្តីរបស់គាត់ជាមួយប្រពន្ធគឺគាត់និយាយដូចមិនសូវច្បាស់លាស់ទេដូនខឹង ដូនអត់ ដូនកាលនិយាយស្តាប់គ្នាមិនបានក៏មានដែរ ដូច្នេះហើយខ្លួនក៏មិនសូវនិយាយជាមួយគាត់ដែរ។

១០. តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ជាក់ ថាខ្លួនត្រូវជាម្តាយបង្កើតរបស់ឈ្មោះ [redacted] ឡា តែពេលកើតមកខ្លួនមានជីវភាពក្រលំបាក ក៏បានឱ្យវាទៅគេ យកទៅចិញ្ចឹម ហើយក្រោយមកអ្នកចិញ្ចឹមវាបានស្លាប់អស់ ទើបពេលមានគ្រួសារជាប្រពន្ធកូនហើយ ក៏ត្រឡប់មករស់នៅក្នុងភូមិឃុំជាមួយខ្លួនទៀត តែប្រពន្ធវាមានជំងឺបេះដូង ដូចមានបញ្ជាក់របស់គ្លីនិកសិរីសោភ័ណ និងមានបញ្ហាពាក់ព័ន្ធនឹងការគិតច្រើន ចង់វង្វេងវង្វាន់ផង និយាយមិនសូវដឹងអីទេ ដូចមានលិខិតពេទ្យ ចុះថ្ងៃទី០៣ ខែឧសភា ឆ្នាំ២០២១។ ចំពោះកូនខ្លួនឈ្មោះ [redacted] ឡា គឺវាធ្វើតែស្រែចំការប៉ុណ្ណោះ ហើយខ្លួនក៏ឱ្យលុយកាក់វាចាយខ្លះដែរ ដោយមិនឱ្យប្តីក្រោយខ្លួនដឹងទេ ព្រោះប្តីខ្លួនគាត់ជាឪពុកចុង មិនសូវចូលចិត្តកូនដើម មានចិត្តចង្អៀតដែរ ខ្លួនក៏មិនដែលលឺ ឬឃើញថាកូនខ្លួនឈ្មោះ [redacted] ឡា ប្រព្រឹត្តបទល្មើស រកស៊ីគ្រឿងញៀនអ្វីនោះទេ ដើម្បីបញ្ជាក់ពីភាពស្អាតស្អំរបស់កូនខ្លួន ខាងអាជ្ញាធរភូមិ ក៏បានធ្វើលិខិតបញ្ជាក់មួយមកផងដែរ ដែលខ្លួននឹងស្នើសុំដាក់បញ្ចូលជាភស្តុតាងផងដែរ។

១១. តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សុភា ឆ្លើយថា ពីមុនខ្លួនមានផ្ទះនៅជិតជាមួយបងប្អូនរបស់ឈ្មោះ [redacted] ឡា តែពេលខ្លួនបានប្តី ខ្លួនក៏ទៅនៅក្បែរផ្សារវិញ តែនៅចេញចូលទៅលេងផ្ទះបងប្អូនរបស់ឈ្មោះ [redacted] ឡា ដដែល ហើយក៏ទៅលេងចំការ ដែលឈ្មោះ [redacted] ឡា ស្នាក់នៅផងដែរ ដូចជាមួយទៅពីរសប្តាហ៍បានទៅម្តង ដើម្បីបេះស្វាយញាំ។ ក្នុងនាមខ្លួនដែលធ្លាប់ទៅលេង និងស្គាល់គ្នាជាមួយឈ្មោះ [redacted] ឡា មិនដែលលឺថាគាត់លក់ថ្នាំញៀនទេ សូម្បីប្រើប្រាស់ក៏ខ្លួនមិនដែលលឺដែរ ហើយពេលខ្លួនទៅលេងក៏មិនដែលឃើញមានអ្នកប្លែកមុខក្មេងៗទៅរកឈ្មោះ [redacted] ឡា ចេញចូលផ្ទះរបស់ឈ្មោះ [redacted] ឡា ដែរ បើមានគឺមានតែអ្នកកាប់ដំឡូងប៉ុណ្ណោះ។ ចម្លើយខ្លួនមានតែប៉ុណ្ណឹងឯង ហើយក៏ជាចម្លើយពិតដែរខ្លួនហ៊ានទទួលខុសត្រូវចំពោះចម្លើយរបស់ខ្លួន។ ខ្លួនរស់នៅក៏មិនដែលលឺថាអ្នកណាលក់ ឬអ្នកណាប្រើប្រាស់ថ្នាំញៀននោះដែរ។

១២. តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ឆ្លើយថា ខ្លួនជាអ្នកជិតរបស់ឈ្មោះ [redacted] ឡា ឃ្លាតគ្នាប្រហែលជាពីរទៅបីផ្ទះប៉ុណ្ណោះ ហើយខ្លួន និងប្តីក៏ជាអ្នកស៊ីឈ្នួលកាប់។ ខ្លួនរស់នៅជិតផ្ទះរបស់ឈ្មោះ [redacted] ឡា មិនដែលឃើញនៅនឹងផ្ទះគាត់ មានសកម្មភាពអ្វីដែលមនុស្សប្លែក ឬ ក្មេង ចេញចូល រកទិញគ្រឿងញៀននោះទេ បើមានគឺមានតែអ្នកទៅកាប់ដំឡូងប៉ុណ្ណោះ ហើយពេលដល់ខែធ្វើស្រែ ក៏ឃើញឈ្មោះ [redacted] ឡា ធ្វើស្រែ និងដល់ខែដំឡូងក៏ធ្វើដំឡូង ចិញ្ចឹមមាន់តិចតួចប៉ុណ្ណោះឯង។ ការរស់នៅក្នុងភូមិ ខ្លួនក៏មិនដែលលឺថាមានអ្នកណាពាក់ព័ន្ធនឹងគ្រឿងញៀនដែរ។ ចម្លើយខ្លួនមានតែប៉ុណ្ណឹងឯង ហើយក៏ជាចម្លើយពិតដែរ ខ្លួនហ៊ានទទួលខុសត្រូវចំពោះចម្លើយរបស់ខ្លួន ។

១៣. តាមរបាយការណ៍លេខ ១៨៩/២១ ការិ.បគញ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ របស់ការិយាល័យប្រឆាំងគ្រឿងញៀន នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ បានសន្និដ្ឋានថា ផ្អែកតាមការស្រាវជ្រាវ

ស៊ើបអង្កេត និងចម្លើយសារភាពរបស់ជនសង្ស័យ ឈ្មោះ [redacted] ឡា ជាអ្នកជួញដូរ និងរក្សាទុកដោយខុសច្បាប់នូវសារធាតុញៀន។

១៤. តាមកំណត់ហេតុចាប់យកវត្ថុតាងលេខ ០១ នបស៥៣ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ និងតាមកំណត់ហេតុបង្ហាញ និងទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ធ្វើនៅអធិការដ្ឋាននគរបាលស្រុកថ្មពួក ដែលបានបង្ហាញវត្ថុតាងដល់ឈ្មោះ [redacted] ឡា ជាថ្នាំញៀនប្រភេទម្សៅក្រាមសថ្លា ចំនួន០១ថង់ ដែលជនសង្ស័យបានលាក់ទុកក្នុងថង់ខ្មៅដាក់ក្នុងអាវមុននឹងយកទៅបោកអ៊ុត និងសំបកថង់ចំនួន០៩ថង់។

១៥. តាមកំណត់ហេតុចាប់យកវត្ថុតាងលេខ ០១ នបស៥៣ ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ និងកំណត់ហេតុបង្ហាញ និងទទួលស្គាល់វត្ថុតាង ចុះថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ ធ្វើនៅអធិការដ្ឋាននគរបាលស្រុកថ្មពួក ដែលបានបង្ហាញវត្ថុតាងដល់ឈ្មោះ [redacted] ឡា ជាថ្នាំគ្រាប់ wy ពណ៌ក្រហមចំនួន០១គ្រាប់ ដែលជនសង្ស័យបានបោះចោលវត្ថុតាងលើដីក្បែរផ្ទះរបស់ខ្លួន។

១៦. តាមកំណត់ហេតុរាប់ ថ្លឹង ធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ ធ្វើនៅការិយាល័យប្រឆាំងគ្រឿងញៀន ឃើញថាថ្នាំញៀនដែលដកហូតជាប្រភេទម្សៅក្រាមសថ្លាចំនួន០១កូនថង់ ស្មើទម្ងន់ ៨៨,៧៥ក្រាម (ថ្លឹងទាំងសំបកថង់) ក្នុងនោះចំនួន០,០១ក្រាម ដើម្បីធ្វើតេស្តនៅសល់ចំនួន ៨៨,៧៤ក្រាម ជាលទ្ធផលដែលបានមកពីការធ្វើតេស្តដោយឧបករណ៍ពិសោធន៍រកសញ្ញាណរកសារធាតុញៀនជំហានដំបូងប្រភេទ ម៉ាកគីតេស្ត ចេញពណ៌ទឹកក្រូច ដែលស្ថិតនៅក្នុងតារាងចំណាត់ថ្នាក់ II សារធាតុហាមឃាត់ក្នុងតារាង នៃឧបសម្ព័ន្ធច្បាប់ត្រួតពិនិត្យគ្រឿងញៀនកម្ពុជាដែលជរមាន។

១៧. ផ្អែកតាមចម្លើយរបស់ជនត្រូវចោទឈ្មោះ [redacted] ឡា ដែលឆ្លើយនៅដំណាក់កាលសមត្ថកិច្ចថា: ខ្លួនចេះរកស៊ីលក់ថ្នាំញៀនអស់រយៈពេលជាងកន្លះឆ្នាំមកហើយ ដោយសារឈ្មោះខ្លួនល្បីពេកខ្លួនក៏ផ្អាកមួយរយៈ។ ដោយថ្នាំញៀនដែលខ្លួនលក់កន្លងមក គឺទិញពីឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា៥២ឆ្នាំ រស់នៅក្នុងប៉ោយប៉ែត ពុំចាំលេខទូរស័ព្ទ។ ថ្នាំញៀនដែលសមត្ថកិច្ចដកហូតនេះ គឺខ្លួនបានទិញពីឈ្មោះ មុំ ភេទស្រី អាយុ៤៣ឆ្នាំ រស់នៅបន្ទាយមានជ័យ មិនចាំលេខទូរស័ព្ទ និងទិញពីឈ្មោះ រី ភេទប្រុស អាយុប្រហែលជា៣២ឆ្នាំ រស់នៅប៉ោយប៉ែត ប្រើប្រាស់លេខទូរស័ព្ទ [redacted]។ កាលពីម្សិលមិញនៅម៉ោងប្រហែលជាពីររសៀល ខ្លួនតេទូរស័ព្ទទៅឈ្មោះ រី ឱ្យផ្ញើថ្នាំមកឱ្យខ្លួនក៏បានទទួលថ្នាំនោះ(ម្សៅក្រាមសថ្លា) គិតជាប្រាក់ចំនួន ៥០០.០០០រៀល ហើយក៏បានយកទៅលាក់ក្នុងអាវ ហើយម្សៅក្រាមសថ្លានេះ ពិតជារបស់ខ្លួនប្រាកដមែន។ ប៉ុន្តែចម្លើយនៅដំណាក់កាលអយ្យការ និងដំណាក់កាលចៅក្រមស៊ើបសួរ ជនត្រូវចោទបានឆ្លើយបដិសេធចម្លើយដែលឆ្លើយនៅដំណាក់កាលសមត្ថកិច្ចទាំងស្រុងថា: ថ្នាំញៀនដែលសមត្ថកិច្ចដកហូតចេញពីខោអាវ ដែលខ្លួនដាក់ឱ្យគេបោកនោះ មិនមែនជារបស់ខ្លួនទេ។ សរបញ្ជាក់ឲ្យឃើញថាចម្លើយដែលជនត្រូវចោទបានឆ្លើយ បដិសេធមិនអាចជឿជាក់បានឡើយ គ្រាន់តែជាចម្លើយឆ្លើយដោះសារគេចវេសពីការចោទប្រកាន់របស់ជនត្រូវចោទតែប៉ុណ្ណោះ ព្រោះមិនមានសាក្សី និងភស្តុតាងច្បាស់លាស់មកបញ្ជាក់ឡើយ។

១៨.ផ្អែកតាមចម្លើយរបស់ជនត្រូវចោទ, កំណត់ហេតុដកហូតរក្សាទុកវត្ថុតាង ,កំណត់ហេតុបង្ហាញ និងទទួលស្គាល់វត្ថុតាង, កំណត់ហេតុចាប់យកវត្ថុតាង, កំណត់ហេតុរាប់ ថ្លឹង ធ្វើតេស្ត និងវេចខ្ចប់វត្ថុតាង, របាយការណ៍របស់មន្ត្រីនគរបាលយុត្តិធម៌ និងឯកសារនានាក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នាដែលបញ្ជាក់ថាជនត្រូវចោទឈ្មោះ [redacted] ឡា ពិតជាបានជួញដូរ និងប្រើប្រាស់ថ្នាំញៀន ដោយទិញពីជនត្រូវចោទឈ្មោះ [redacted] មុំ ហៅមុំ, ជនត្រូវចោទឈ្មោះធី និងជនត្រូវចោទឈ្មោះ រី ប្រាកដមែន។

១៩.ការផ្តល់សម្រាប់លក់ ការលក់ ការទិញ ដើម្បីលក់ ឬដោះដូរ ការដោះដូរដោយខុសច្បាប់នូវសារធាតុញៀន របស់ជនត្រូវចោទឈ្មោះ [redacted] ឡា ត្រូវបានច្បាប់កំណត់ថាជាបទល្មើស ជួញដូរដោយខុសច្បាប់នូវ



Scanned with CamScanner

សារធាតុញៀន ដែលមានថែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២០.អំពើដែលប្រើប្រាស់នូវសារធាតុញៀន របស់ជនត្រូវចោទឈ្មោះ [redacted] ឡា ត្រូវបានច្បាប់កំណត់ជាជាបទល្មើស ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដែលមានថែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២១.ជនត្រូវចោទជានីតិជនមានសមត្ថភាពក្នុងការយល់ដឹងគ្រប់គ្រាន់ ដែលអាចទទួលខុសត្រូវចំពោះអំពើប្រព្រឹត្តរបស់ខ្លួន។

២២.អំពើប្រព្រឹត្តរបស់ជនត្រូវចោទស្តែងឡើងដោយចេតនាទុច្ចរិត ដែលអំពើនេះត្រូវបានច្បាប់រដ្ឋការពារយ៉ាងតឹងរឹងចំពោះជនដែលប្រព្រឹត្ត ព្រោះអំពើនេះធ្វើឲ្យប៉ះពាល់ដល់របៀបរៀបរយសង្គម ហើយត្រូវបានច្បាប់បញ្ញត្តថាជាបទល្មើសព្រហ្មទណ្ឌ។

២៣.ក្រោយពេលប្រព្រឹត្តបទល្មើសរួចមកជនត្រូវចោទឈ្មោះ វី និងឈ្មោះ ធី (គ្មានអត្តសញ្ញាណ) បានរត់គេចខ្លួនបាត់រហូតដល់ពេលនេះ នៅតែមិនស្គាល់អត្តសញ្ញាណ និងបានពិនិត្យសំណុំរឿង ឯកសារពាក់ព័ន្ធនានាហើយនោះ ឃើញថាមិនអាចរកឃើញសារតាជាតិគ្រប់គ្រាន់ របស់ជនត្រូវចោទឈ្មោះ វី និងឈ្មោះ ធី បានទេ គប្បីលើកលែងចោទប្រកាន់តាមមាត្រា ២៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២៤.តាមដីកាសន្និដ្ឋានស្ថាពរលេខ ២៤៣ អយក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០២១ តំណាងអយ្យការបានសម្រេចប្តឹងសុំបញ្ជូនជនត្រូវចោទឈ្មោះ [redacted] ឡា ភេទប្រុស ឆ្នាំកំណើត១៩៨៣ (ក្នុងឃុំ) ទៅជំនុំជម្រះពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៤០ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងជនត្រូវចោទឈ្មោះ [redacted] ហៅមុំ ភេទស្រី ថ្ងៃខែឆ្នាំកំណើត ០៩-០៦-១៩៧៨ (គេចខ្លួន) ទៅជំនុំជម្រះ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបានសម្រេចលើកលែងចោទប្រកាន់ជនត្រូវចោទឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា៤២ឆ្នាំ និងឈ្មោះ វី ភេទប្រុស អាយុប្រហែល៣២ឆ្នាំ (គ្មានអត្តសញ្ញាណ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

-តាមមាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដីកាដំណោះស្រាយបញ្ចប់ការឃុំខ្លួនជាបណ្តោះអាសន្ន។ តែដើម្បីធានារក្សាជនត្រូវចោទទុកជូនតុលាការចាត់ការតាមនីតិវិធី គប្បីចេញសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយរក្សាជនត្រូវចោទ ឲ្យនៅជាប់ឃុំជាបណ្តោះអាសន្ន រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

## ហេតុដូច្នេះសម្រេច

១.លើកលែងចោទប្រកាន់លើជនត្រូវចោទឈ្មោះ ធី ភេទប្រុស អាយុប្រហែលជា៤២ឆ្នាំ និងឈ្មោះ វី ភេទប្រុស អាយុប្រហែល៣២ឆ្នាំ (គ្មានអត្តសញ្ញាណ) ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិវល្លិប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយ មានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានថែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។



Scanned with CamScanner

២.បញ្ជូនជនត្រូវចោទឈ្មោះ [redacted] ឡា ភេទប្រុស កើតឆ្នាំ១៩៨៣ សញ្ជាតិខ្មែរ (អត្តសញ្ញាណខាងលើ) (ក្នុងឃុំ) ទៅជំនុំជម្រះ ពីបទ ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិល្វើប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៥ ចំណុច៦ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣.បញ្ជូនជនត្រូវចោទឈ្មោះ [redacted] មុំ ភេទស្រី ថ្ងៃខែឆ្នាំកំណើត០៩-០៦-១៩៧៨ សញ្ជាតិខ្មែរ (អត្តសញ្ញាណ ខាងលើ) (គេចខ្លួន) ទៅជំនុំជម្រះ ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិល្វើប្រេង ឃុំគោករមៀត ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី០៨ ខែមីនា ឆ្នាំ២០២១ បទល្មើសដែលមានចែង និងឱ្យផ្តន្ទាទោសតាមមាត្រា ៤០ កថាខណ្ឌ៣ និងកថាខណ្ឌ៤ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៤.បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ២៦០ ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០២១ និងបញ្ជីរាយនាមជនដែលទាក់ទិន ព្រមទាំងវត្ថុតាងក្នុងសំណុំរឿងនេះទៅសាលាដំបូងខេត្តបន្ទាយមានជ័យ ដើម្បីជំនុំជម្រះតាមច្បាប់។

៥.រក្សាទុកជនត្រូវចោទឈ្មោះ [redacted] ឡា (អត្តសញ្ញាណខាងលើ) ដែលត្រូវបានឃុំខ្លួនបណ្តោះអាសន្នតាមដីកាបង្គាប់ឲ្យឃុំខ្លួនបណ្តោះអាសន្នលេខ ២០០ ព្រទ.III-ច៧/២១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២១ ដើម្បីធានារក្សាជនជាប់ចោទទុកជូនតុលាការតាមនីតិវិធី រហូតដល់ពេលចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។

ថ្ងៃ ព្រហ ៨ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅបន្ទាយមានជ័យ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២១

**ក្រឡាបញ្ជី** **ចៅក្រមស៊ើបសួរ**

[redacted] [redacted]

**បានទទួលដំណឹង**

ថ្ងៃ ចន្ទ ១២ កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស២៥៦៥

ធ្វើនៅបន្ទាយមានជ័យ, ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១

**ជ.ព្រះរាជអាជ្ញា**

[redacted]

**ព្រះរាជអាជ្ញារង**

Scanned with CamScanner